ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ស្ពឺ**

សំណុំរឿងរដ្ឋប្បវេណីលេខៈ ៣២៩

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩

សាលក្រមលេខៈ ១២ "ខ"

ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តកំពង់ស្ពឺ

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

**លោក [redacted] អនុប្រធាននិងជាចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ**

**ក្រឡាបញ្ជី**

**លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ**

**-ដើមចោទឈ្មោះ** [redacted] គឹមឡុង ភេទស្រី អាយុ ៥៩ឆ្នាំ ទីលំនៅសព្វថ្ងៃនៅ [redacted]។

**-មេធាវីតំណាងដោយអាណត្តិមានលោក** [redacted] **លោកមេធាវី** [redacted], **លោកមេធាវី** [redacted], **លោកមេធាវី** [redacted] **លោកមេធាវី** [redacted] ។

**-ចុងចម្លើយឈ្មោះ** [redacted] ចន្ទ ភេទស្រី អាយុ ៤៧ឆ្នាំ ទីលំនៅសព្វថ្ងៃនៅ [redacted]។

**-សហចុងចម្លើយឈ្មោះ** [redacted] ចិន្តា ភេទស្រី អាយុ ៤៧ឆ្នាំ ទីលំនៅសព្វថ្ងៃនៅនៅ [redacted]។

**ដែលមានកម្មវត្ថុបណ្តឹង:**

១-សុំចេញសាលក្រមសម្រេចឲ្យឈ្មោះ [redacted] ចន្ទ ឈ្មោះ [redacted] ចិន្តា ឈ្មោះ [redacted] ចំណាន និងបក្សពួក សងប្រាក់ចំនួន ២០,២០០(ពីរម៉ឺនពីររយ)ដុល្លារអាមេរិក។

២-សុំឲ្យសងជម្ងឺចិត្តចំនួន ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក។

៣-សុំសាលក្រមសម្រេចមានប្រសិទ្ធិភាពអនុវត្តភ្លាម ។

ក្រោយពីទទួលពិនិត្យបណ្តឹង និងបានធ្វើការពន្យល់ណែនាំតាមរបៀបចាត់ចែងនៃក្រមនីតិវិធីរដ្ឋប្បវេណីដល់ភាគីទាំងសងខាងរួចបានធ្វើការអះអាង ។



Scanned with CamScanner

# <u>អង្គហេតុ និងចំណុចវិវាទ</u>

ទី១-ការទាមទាររបស់ដើមចោទ:

១-សុំចេញសាលក្រមសម្រេចឱ្យឈ្មោះ [redacted] ចន្ធូ ឈ្មោះ [redacted] ចិន្តា ឈ្មោះ [redacted] ចំណាន និងបក្សពួក សងប្រាក់ចំនួន ២០,២០០(ពីរម៉ឺនពីររយ)ដុល្លារអាមេរិក។

២-សុំឱ្យសងជម្ងឺចិត្តចំនួន ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក។

៣-សុំសាលក្រមសម្រេចមានប្រសិទ្ធិភាពអនុវត្តភ្លាម ។

ទី២-ដំណើររឿងក្តី

ក-<u>ការអះអាងរបស់ភាគីដើមចោទ</u>

-លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] គីមឡេង បានធ្វើសេចក្តីថ្លែងការណ៍ថា: កូនក្តីរបស់ខ្ញុំបាទឈ្មោះ [redacted] គីមឡេង បានឱ្យប្រាក់ទៅឈ្មោះដូចមានរាយលំអិតដូចខាងក្រោម:

១/ឈ្មោះ [redacted] ចន្ធូ បានខ្ចីប្រាក់ចំនួន ៣,០០០(បីពាន់)ដុល្លារអាមេរិក

២/ឈ្មោះ [redacted] ចិន្តា និងឈ្មោះ [redacted] ចន្ធូ បានខ្ចីប្រាក់ចំនួន ២,០០០(ពីរពាន់)ដុល្លារអាមេរិក នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៨ ។

៣/ឈ្មោះ [redacted] ចិន្តា ខ្ចីប្រាក់ចំនួន ៣០០០(បីពាន់)ដុល្លារអាមេរិក ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២ ។

៤/ឈ្មោះ [redacted] ចិន្តា និងឈ្មោះ [redacted] ចន្ធូ ខ្ចីប្រាក់ចំនួន ៩២០០(ប្រាំបួនពាន់ពីររយ)ដុល្លារអាមេរិក ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ ។

៥/ឈ្មោះ [redacted] ចិន្តា ខ្ចីប្រាក់ចំនួន ១០០០(មួយពាន់)ដុល្លារអាមេរិក ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៨ ។

៦/ឈ្មោះ [redacted] ចិន្តា និងឈ្មោះ [redacted] ចន្ធូ ខ្ចីប្រាក់ចំនួន ២០០០(មួយពាន់)ដុល្លារអាមេរិក ។

នៅពេលទទួលបានប្រាក់កម្ចីដល់ដៃរួចហើយ ឈ្មោះខាងលើនេះមិនបានយកប្រាក់ដើម និងការប្រាក់មកសងឱ្យកូនក្តីរបស់ខ្លួនវិញឡើយ ។ ដោយសារការសង្ស័យកូនក្តីខ្លួនក៏បានតាមរកកូនបំណុលដូចមានរាយនាមខាងលើ តែពុំអាចរកឃើញកូនកំណុលទាំងអស់នោះឃើញឡើយ ហើយក៏មិនដឹងថា កូនបំណុលទាំងនោះគេចខ្លួនទៅណា និងអស់មធ្យោបាយក្នុងការតាមរកកូនបំណុលរបស់កូនក្តីខ្លួន ក៏បានហៅឈ្មោះ [redacted] ចិន្តា និងឈ្មោះ [redacted] ចន្ធូ មកសួរនាំ ទើបអ្នកទាំងពីរអ្នកនេះយកវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៧០៦០៤.០៣៩២ និងលេខ ០៥០៧០៦០៤.០៣៤៦ មកប្រគល់ឱ្យកូនក្តីរបស់ខ្លួនគ្រប់គ្រង ដោយសាមីខ្លួនម្ចាស់ដីពុំបានយកប្លង់ទាំងពីរនេះ យកមកប្រគល់ដល់ដៃកូនក្តីខ្លួននោះឡើយ ។ ដោយមានក្តីបារម្ភពីរឿងដីទាំងពីរកន្លែងនេះ កូនក្តីរបស់ខ្លួនបានព្យាយាមតាមរកម្ចាស់ដី តែពុំមានលទ្ធភាពរកឃើញសោះឡើយ ។ កូនក្តីខ្លួនមានឆន្ទៈដោះស្រាយបញ្ហាទំនាស់រវាងកូនបំណុល ម្ចាស់ដីដោយសន្តិវិធី តែរហូតពេលនេះមានរយៈពេលជាច្រើនឆ្នាំ ហើយនៅតែមិនទាន់រកឃើញម្ចាស់ដី និងកូនបំណុលបានធ្វើឱ្យខូចខាត និងបាត់បង់ផលប្រយោជន៍របស់កូនក្តីខ្លួនយ៉ាងធ្ងន់ធ្ងរបំផុត ។

ខ-<u>ការអះអាងរបស់ភាគីចុងចម្លើយ</u>

-តុលាការបានបញ្ជូនដីកាកោះតាមរយៈប្រៃសណីយ៍ប្រចាំខេត្តកំពង់ស្ពឺ និងមានការបញ្ជាក់ពីលោក [redacted] មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនបញ្ជាក់ថា ឈ្មោះ [redacted] ចន្ធូ និងឈ្មោះ [redacted] ចិន្តា បានផ្លាស់ទីលំនៅចេញពីភូមិនេះ ហើយមិនដឹងថារស់នៅទីណាឡើយ ។

គ-ចំណុចវិវាទ: គ្មាន ។

-ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា កូនក្តីរបស់ខ្ញុំបាទឈ្មោះ [redacted] គីមឡេង បានឲ្យប្រាក់ទៅឈ្មោះដូចមានរាយលំអិតដូចខាងក្រោម:

១/ឈ្មោះ [redacted] ចន្ធូ បានខ្ចីប្រាក់ចំនួន ៣,០០០(បីពាន់)ដុល្លារអាមេរិក

២/ឈ្មោះ [redacted] ចិន្តា និងឈ្មោះ [redacted] ចន្ធូ បានខ្ចីប្រាក់ចំនួន ២,០០០(ពីរពាន់)ដុល្លារអាមេរិក នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៨ ។

៣/ឈ្មោះ [redacted] ចិន្តា ខ្ចីប្រាក់ចំនួន ៣០០០(បីពាន់)ដុល្លារអាមេរិក ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២ ។

៤/ឈ្មោះ [redacted] ចិន្តា និងឈ្មោះ [redacted] ចន្ធូ ខ្ចីប្រាក់ចំនួន ៩២០០(ប្រាំបួនពាន់ពីររយ)ដុល្លារអាមេរិក ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ ។

៥/ឈ្មោះ [redacted] ចិន្តា ខ្ចីប្រាក់ចំនួន ១០០០(មួយពាន់)ដុល្លារអាមេរិក ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៨ ។

៦/ឈ្មោះ [redacted] ចិន្តា និងឈ្មោះ [redacted] ចន្ធូ ខ្ចីប្រាក់ចំនួន ២០០០(មួយពាន់)ដុល្លារអាមេរិក ។

នៅពេលទទួលបានប្រាក់កម្ចីដល់ដៃរួចហើយ ឈ្មោះខាងលើនេះមិនបានយកប្រាក់ដើម និងការប្រាក់មកសងឲ្យកូនក្តីរបស់ខ្លួនវិញឡើយ ។ ដោយសារការសង្ស័យកូនក្តីខ្លួនក៏បានតាមរកកូនបំណុលដូចមានរាយនាមខាងលើ តែពុំអាចរកឃើញកូនកំណុលទាំងអស់នោះឃើញឡើយ ហើយក៏មិនដឹងថា កូនបំណុលទាំងនោះគេចខ្លួនទៅណា និងអស់មធ្យោបាយក្នុងការតាមរកកូនបំណុលរបស់កូនក្តីខ្លួន ក៏បានហៅឈ្មោះ [redacted] ចិន្តា និងឈ្មោះ [redacted] ចន្ធូ មកសួរនាំ ទើបអ្នកទាំងពីរអ្នកនេះយកវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៧០៦០៤.០៣៩២ និងលេខ ០៥០៧០៦០៤.០៣៤៦ មកប្រគល់ឲ្យកូនក្តីរបស់ខ្លួនគ្រប់គ្រង ដោយសាម៉ីខ្លួនម្ចាស់ដីពុំបានយកប្លង់ទាំងពីរនេះ យកមកប្រគល់ដល់ដៃកូនក្តីខ្លួននោះឡើយ ។ ដោយមានក្តីបារម្ភណ៍ពីរឿងដីទាំងពីរកន្លែងនេះ កូនក្តីរបស់ខ្លួនបានព្យាយាមតាមរកម្ចាស់ដី តែពុំមានលទ្ធភាពរកឃើញសោះឡើយ ។ កូនក្តីខ្លួនមានឆន្ទៈដោះស្រាយបញ្ហាទំនាស់រវាងកូនបំណុល ម្ចាស់ដីដោយសន្តិវិធី តែរហូតពេលនេះមានរយៈពេលជាច្រើនឆ្នាំ ហើយនៅតែមិនទាន់រកឃើញម្ចាស់ដី និងកូនបំណុលបានធ្វើឲ្យខូចខាត និងបាត់បង់ផលប្រយោជន៍របស់កូនក្តីខ្លួនយ៉ាងធ្ងន់ធ្ងរបំផុត ។

-ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការបានធ្វើការកោះហៅសហចុងចម្លើយឈ្មោះ [redacted] ចិន្តា និងឈ្មោះ [redacted] ចន្ធូ ដោយតុលាការបានចេញដីកាកោះហៅចុងចម្លើយគ្រប់នីតិវិធី និងមានការបញ្ជាក់លោក [redacted] មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន បានសហការជាមួយលោកមេភូមិសាមគ្គី បានយកដីកានេះទៅប្រគល់ឲ្យឈ្មោះ [redacted] ចិន្តា និងឈ្មោះ [redacted] ចន្ធូ ប៉ុន្តែឈ្មោះនេះបានចាកចេញពីភូមិ និងមិនដឹងថារស់នៅទីណាទេ ។

-ឯកសារភស្តុតាងមានដូចជា:

-កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១២ រវាងឈ្មោះ [redacted] គីមឡេង និងឈ្មោះ [redacted] ចិន្តា ។

-កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ រវាងឈ្មោះ [redacted] គីមឡេង និងឈ្មោះ [redacted] ចន្ធូ ។

-កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១២ រវាងឈ្មោះ [redacted] គីមឡេង និងឈ្មោះ [redacted] ចិន្តា ។

-កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១២ រវាងឈ្មោះ [redacted] គីមឡេង និងឈ្មោះ [redacted] ចន្ធូ , [redacted] ចិន្តា ។

-កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១២ រវាងឈ្មោះ [redacted] គីមឡេង និងឈ្មោះ [redacted] ចន្ធូ , [redacted] ចិន្តា ។



Scanned with CamScanner

តាមកិច្ចសន្យាខ្ចីប្រាក់ ដែលដើមចោទបានដាក់ជូនតុលាការពិនិត្យអាចបញ្ជាក់បានថា សហចុងចម្លើយឈ្មោះ [redacted] ចិន្តា និងឈ្មោះ [redacted] ចន្ធូ ពិតជាបានខ្ចីប្រាក់ពីដើមចោទឈ្មោះ [redacted] គីមឡេង ចំនួន ២០២០០(ពីរម៉ឺនពីររយ)ដុល្លារអាមេរិក ពិតប្រាកដមែន។

-ដើមចោទបានទាមទារសំណងជម្ងឺចិត្តចំនួន ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក តុលាការគប្បីសម្រេចតាមច្បាប់។

-ដើមចោទបានទាមទារសុំឱ្យតុលាការអនុវត្តបណ្តោះអាសន្ន ប៉ុន្តែតុលាការមិនអាចសម្រេចបាននោះទេ ដោយសារតែភាគីសហចុងចម្លើយចាត់ទុកបានទទួលដំណឹងពីដីកាកោះរបស់តុលាការ និងអវត្តមានគ្រប់នីតិវិធី ដោយតុលាការបានអនុវត្តការបញ្ជូនតាមនីតិវិធីចប់សព្វគ្រប់ ហើយប្រសិនបើតុលាការសម្រេចអនុវត្តបណ្តោះអាសន្ននោះ អាចធ្វើឱ្យប៉ះពាលដល់ផលប្រយោជន៍ស្របច្បាប់របស់សហចុងចម្លើយឈ្មោះ [redacted] ចន្ធូ និងឈ្មោះ [redacted] ចិន្តា ដូចនេះតុលាការគប្បីមិនលើក ចំណុចទី ៣ នៃកម្មវត្ថុបណ្តឹងមកធ្វើការ ពិចារណាសម្រេចតាមច្បាប់ឡើយ ។

-ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមបញ្ញត្តិច្បាប់មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

<u>**សាលាដំបូងខេត្តកំពង់ស្ពឺ**</u>

<u>**ជំនុំជម្រះសេចក្តី**</u>

១-ទទួលស្គាល់ពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] គីមឡេង ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៩ ត្រឹមត្រូវតាមទម្រង់ច្បាប់។

២-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ចន្ធូ ភេទស្រី អាយុ ៤៧ឆ្នាំ ឈ្មោះ [redacted] ចិន្តា ភេទស្រី អាយុ ៤៧ឆ្នាំ សងប្រាក់ចំនួន ២០២០០(ពីរម៉ឺនពីររយ)ដុល្លារអាមេរិក ទៅដើមចោទឈ្មោះ [redacted] គីមឡេង ។

៣-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ចន្ធូ ភេទស្រី អាយុ ៤៧ឆ្នាំ ឈ្មោះ [redacted] ចិន្តា ភេទស្រី អាយុ ៤៧ឆ្នាំ សងសំណងជម្ងឺចិត្តចំនួន ៣,០០០(បីពាន់)ដុល្លារអាមេរិក ទៅដើមចោទឈ្មោះ [redacted] គីមឡេង ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីសហចុងចម្លើយ។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផល និងប្រកាសជាសាធារណៈ នាថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០២០ ចំពោះមុខភាគីដើមចោទឈ្មោះ [redacted] គីមឡេង និងកំបាំងមុខសហចុងចម្លើយឈ្មោះ [redacted] ចន្ធូ និងឈ្មោះ [redacted] ចិន្តា បើកសិទ្ធប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់។

ចៅក្រម

ហត្ថលេខា និងត្រា [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ១០កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

កំពង់ស្ពឺ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០២០

បានឃើញ

ចៅក្រម

[redacted]

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner